# មេរៀនទី ១៣៤: ស្តេចអាប់សាឡុំមប៉ុនប៉ងដណ្តើមរាជ្យ

## ២ សាំយូអែល ១៥:១-១២, ១៧:១-១២, ១៨:១-១៨

**គោលបំណង៖** យើងលើកដំកើងព្រះដោយការទុកទ្រង់ជាទី១។

**ខគម្ពីរចងចាំ៖ ម៉ាថាយ ៦:៣៣** *"ចូរស្វែងរកនគរ និងសេចក្តីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះនឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ជីវិតដែលមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួនរបស់ព្រះយេស៊ូវបានធ្វើឲ្យពិភពលោកមានភាពខុសគ្នាសម្រាប់យើង។ តើអាកប្បកិរិយាគិតតែពីខ្លួនឯងប៉ះពាល់ដល់ទំនាក់ទំនងយ៉ាងដូចម្តេច? តើការធ្វើតាមគំរូព្រះយេស៊ូវ ដែលមិនគិតប្រយោជន៍ផ្ទាល់ខ្លួនអាចពង្រឹងពួកគេយ៉ាងដូចម្តេច? តើយើងអាចរក្សាអាកប្បកិរិយាព្រះគ្រីស្ទជាកណ្តាលបានដោយរបៀបណា? ដោយសម្លឹងមើលទៅព្រះគ្រីស្ទគ្រប់ពេលវេលា។ អរគុណព្រះសម្រាប់ការបញ្ជូនព្រះយេស៊ូវ ដែលនាំយើងទៅកាន់ទំនាក់ទំនងកាន់តែប្រសើរឡើង ដោយបង្ហាញយើងពីរបៀបប្រព្រឹត្តចំពោះអ្នកដទៃ ដោយសេចក្តីស្រឡាញ់ដែលមិនគិតតែពីខ្លួនឯង ពោលគឺរបៀបដែលទ្រង់ប្រព្រឹត្តចំពោះយើង។

**ចំរៀង៖** ១. ស្តេចលើស្តេច ២. ចូរប្រយ័ត្ននឹងភ្នែកតូចអ្នក ៣. ខ្ញុំនឹងទុកចិត្តទ្រង់

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «ដណ្តើមស្លឹកឈើ»**

**សម្ភារៈដែលត្រូវការ៖** មែកឈើ១មែក



១. ចែកកុមារជា ២ក្រុម

២. ដាក់មែកឈើនៅចំកណ្តាល ដោយឲ្យកុមារឈរទល់មុខគ្នា

៣. គ្រូត្រូវដាក់លេខរៀងឲ្យគូរនីមួយៗ។

៤. នៅពេលដែលគ្រូហៅលេខ កុមារដែលលឺលេខរៀងរបស់ខ្លួន ពួកគេត្រូវរត់ឲ្យលឿនមកកន្លែងដាក់មែកឈើ។ ពួកគេត្រូវដណ្តើមមែកឈើនោះទៅកាន់កន្លែងដើមវិញ ដោយមិនត្រូវឲ្យកុមារដែលមកពីក្រុមម្ខាងទៀតប៉ះគេបាននោះទេ។

៥. ឧទាហរណ៍៖ ប្រសិនបើគ្រូហៅ "គូរទី៣!" នោះអ្នកដែលមានលេខរៀងទី៣ ត្រូវរត់មកដណ្តើមមែកឈើនោះ ហើយរត់ត្រឡប់ទៅកាន់ក្រុមគេវិញឲ្យបានលឿនតាមដែលអាចធ្វើទៅបាន។

៦. ប្រសិនបើក្រុមម្ខាងទៀតប៉ះគេបាននោះគេនឹងចាញ់ល្បែងនេះ។

៧. បន្តលេងល្បែងនេះ រហូតដល់កុមារទាំងអស់បានលេងគ្រប់ៗគូរ។

៨. ក្រុមណាដែលទទួលបានពិន្ទុច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។

៩. តាមរយៈការដណ្តើមស្លឹកឈើនេះអ្នកគ្រូនិងបង្ហាញប្អូននៅក្នុងសាច់រឿង នៅថ្ងៃនេះអ្នកគ្រូនិងទិទានរឿងមួយ

ក្នុងព្រះគម្ពីរអំពីកូនណ្ដើមរាជ្យពីឪពុក ។

## ៤. ការណែនាំមេរៀន

ពេលដែលអ្នកភ្ញាក់ពីគេង តើអ្នកគិតអីមុនគេ? តើអ្នកនឹងគិតថាត្រូវញាំអីពេលព្រឹក? គិតរឿងទៅសាលារៀន? ថ្ងៃនេះយើងនឹងរៀនពីការលើកតម្កើងព្រះដោយទុកទ្រង់ជាទី១។ ពេលដែលយើងគោរពនរណាម្នាក់ យើងបង្ហាញកាយវិការឬប្រើពាក្យសំដី ដែលបង្ហាញថាបុគ្គលម្នាក់នោះអស្ចារ្យប៉ុណ្ណា។ ឧទាហរណ៍៖ ដូចជានៅពេលដែលអ្នកគោរពឪពុកម្ដាយ អ្នកបង្ហាញនិងនិយាយថាពួកគាត់សំខាន់ប៉ុណ្ណា ពីព្រោះពួកគាត់ជាឪពុកម្ដាយរបស់អ្នក ហើយពួកគាត់យកចិត្តទុកដាក់ចំពោះអ្នក។ វិធីមួយដែលយើងនាំការគោរព និងលើកតម្កើងព្រះ គឺដោយការទុកព្រះជាទី១នៅក្នុងជីវិតយើង ដោយការទៅព្រះវិហារសរសើរតម្កើងព្រះ ជំនួសឲ្យការទៅធ្វើអ្វីផ្សេងឧទាហរណ៍៖ដូចជាអ្នកកំពុងនៅទីនេះដើម្បីគោរពលើកតម្កើងព្រះដោយអ្នកទុកទ្រង់ជាទី១។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ដាវីឌគឺជាស្ដេចសាសន៍អ៊ីស្រាអែល ហើយគាត់គឺជាស្ដេចដ៏ល្អ។ ដាវីឌស្រឡាញ់ព្រះ និងស្ដាប់បង្គាប់ព្រះ ។ ប៉ុន្តែនៅពេលដាវីឌនៅធ្វើជាស្ដេច កូនប្រុសម្នាក់របស់ដាវីឌបានសំរេចចិត្តចង់ក្លាយទៅជាស្ដេចជំនួសគាត់។ កូនគាត់ម្នាក់នោះមានឈ្មោះថា អាប់សាឡុំម។ អាប់សាឡុំមបានសំរេចចិត្តចង់ឲ្យប្រជាជនដើរតាមគាត់ជំនួសស្ដេចដាវីឌ។ អាប់សាឡុំមបានធ្វើពុតជារួសរាយរាក់ទាក់ជាមួយនឹងប្រជាជនទាំងអស់នោះ តែអ្វីដែលគាត់ចង់បានពិតប្រាកដនោះ គឺចង់ឲ្យប្រជាជនទាំងអស់គ្នាជួយគាត់ឲ្យក្លាយទៅជាស្ដេច។

អាប់សាឡុំមទទួលបានអ្នកដើរតាមដាវីឌមួយចំនួនមកដើរតាមគាត់ជំនួសវិញ។ ហើយមានប្រជាជនជាច្រើននៅខាងអាប់សាឡុំម។ ថ្ងៃមួយអាប់សាឡុំម និងអ្នកដើរតាមគាត់បានវាយប្រហារស្ដេចដាវីឌ និងអ្នកដើរតាមស្ដេចដាវីឌ។ អាប់សាឡុំមច្បាស់ណាស់ថាគាត់នឹងឈ្នះ ហើយនឹងក្លាយជាស្ដេចបន្ទាប់របស់សាសន៍អ៊ីស្រាអែល។ ប៉ុន្តែព្រះមិនចង់ឲ្យរាស្ត្ររបស់ទ្រង់មានភាពអាត្មានិយមឡើយ។ ព្រះចង់ឲ្យរាស្ត្ររបស់ទ្រង់តែងតែទុកព្រះអង្គជាទី១។ អាប់សាឡុំមមិនបានយកព្រះជាទី១ទេ គាត់ជាមនុស្សអាត្មានិយមខ្លាំងណាស់។ ស្ដេចដាវីឌទុកព្រះជាទី១ និងលើកតម្កើងព្រះ ហើយគាត់បានឈ្នះការប្រយុទ្ធ។ គាត់នៅតែជាស្ដេចហើយអាប់-សាឡុំមមិនបានក្លាយទៅជាស្ដេចទេ។

យើងលើកតម្កើងព្រះដោយទុកព្រះជាទី១ មានន័យថាត្រូវរស់នៅតាមផ្លូវដែលព្រះចង់ឲ្យយើងរស់នៅ។ ព្រះចង់ឲ្យយើងសរសើរដំកើងព្រះអង្គ។ តើយើងអាចលើកដំកើងព្រះដោយទុកព្រះជាទី១បានដែរឬទេ?

## ៦. សំនួរពិភាក្សា

១. តើនរណាជាស្ដេចរបស់អ៊ីស្រាអែល? *ស្ដេចដាវីឌ*

២. តើអ្នកណាចង់ក្លាយជាស្ដេចរបស់អ៊ីស្រាអែល? *អាប់សាឡុំម ជាកូនប្រុសរបស់ស្ដេចដាវីឌ*

៣. ហេតុអ្វីបានជាព្រះជួយស្ដេចដាវីឌឲ្យឈ្នះអាប់សាឡុំម?

*ដោយសារស្ដេចដាវីឌបានលើកតម្កើងព្រះដោយទុកព្រះជាទី១*

| |
|---|
| ៤. តើអ្នកអាចធ្វើអ្វីខ្លះដើម្បីលើកតម្កើងព្រះដោយទុកព្រះជាទី១? *ស្រឡាញ់ព្រះ សប្បុរសចំពោះអ្នកដទៃ ស្តាប់បង្គាប់ឪពុកម្តាយយើង សរសើរតម្កើងព្រះ និងធ្វើទង្វើល្អៗជាច្រើនទៀត* |

## ៧. ល្បែងកំសាន្ត «លួចសោលោកយាយ»



**សម្ភារៈដែលត្រូវការ៖** កូនសោរ១ចង្កោម ម៉ាសឬកន្សែង

១. រកអ្នកចាំទីម្នាក់អង្គុយតំណាងជា "លោកយាយ"

២. ចែកកុមារជា២ក្រុមស្មើគ្នាអង្គុយជាជួរ

៣.ឲ្យ"លោកយាយ"អង្គុយនៅចំកណ្តាលរវាងក្រុមទាំងពីរ។ បិតភ្នែក "លោកយាយ"

៤. ដាក់ចង្កោមសោរនៅពីមុខ"លោកយាយ"

៥. ក្រុមនីមួយៗត្រូវឲ្យកុមារម្នាក់មកទាញយកសោរដែលនៅពីមុខ "លោកយាយ" ដោយស្ងៀមស្ងាត់។

៦. បន្ទាប់ពីសោរត្រូវបានលួចរួចនោះ "លោកយាយ" ត្រូវទាយថា តើសោរនោះនៅក្រុមខាងឆ្វេងឬខាងស្តាំ។ ប្រសិនបើ "លោកយាយ" ទាយខុស នោះក្រុមដែលបានលួចសោរនោះនឹងទទួលបានមួយពិន្ទុ។ ប៉ុន្តែបើ "លោកយាយ" ទាយត្រូវនោះ ពួកគេមិនទទួលបានពិន្ទុនោះទេ។

៧. ក្រុមណាដែលទទួលបានពិន្ទុច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។

៨. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា នៅពេលដែលយើងលួចអ្វីមួយនោះ យើងបានបង្ហាញថា យើងមិនបានគោរពចាស់ទុំទេ ហើយយើងក៏មិនបានទុកព្រះជាទីមួយដែរ។ ព្រះនឹងសប្បាយព្រះទ័យនៅពេលដែលយើងទុកទ្រង់ជាទី១ ដោយការបង្ហាញសេចក្តីស្រលាញ់របស់យើងចំពោះអ្នកដទៃ។

## ៨. ខគម្ពីរចងចាំ ម៉ាថាយ ៦:៣៣

## ៩. ហាត្ថកម្ម សូមផាត់ពណ៌រូបភាព "ដាវីឌទុកព្រះជាទី១"

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# ដាវីឌទុកព្រះជាទី១



សូមសរសេរខគម្ពីរចងចាំ៖